**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ៖.....៣៧០.....អ.ជ.ប.ជ.អ.

# សេចក្តីសម្រេចចិត្ត
## នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩
ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥បានដំណើរការ រយៈពេលមួយព្រឹកពេញ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល ចំនួនសរុប១៨០រូប។

កិច្ចប្រជុំបានថ្លែងអំណរគុណនិងកោតសរសើរចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងចូលរួមយ៉ាងសកម្មក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៥ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវបន្តជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកានានាដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍និងជំងឺអេដស៍ ការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្តប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ថែទាំព្យាបាលឱ្យបានទាន់ពេលវេលា ទូលំទូលាយ និងតាមលទ្ធភាព។

២- គ្រប់រដ្ឋបាលរាជធានី ខេត្តត្រូវគាំទ្ររៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានចប់សព្វគ្រប់១០០% នាដំណាច់ឆ្នាំ២០២៥។

៣- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវប្រើប្រាស់ថវិកា ៨០លានរៀល ៦០លានរៀល ៤០លានរៀល ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជជូនជារៀងរាល់ឆ្នាំ លើការងារអេដស៍ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។



អាសយដ្ឋាន៖ អគារលេខ១៦ ផ្លូវលេខ២៧១កែង១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក ទូរស័ព្ទលេខ០៧៧ ៩៣៣ ៥៥៩ និង ០៨៦ ៦៣០ ៥៦៤
Tel: (855) 77 933 559 / 86 630 564 • E-mail: info@naaa.gov.kh • Website: www.naaa.gov.kh

៤- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ណែនាំជួយសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជាដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គម ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស(MSM) អ្នកបំប្លែងភេទ(TG) ស្ត្រីបម្រើក្នុងសេវាកម្សាន្ត(EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) ដល់ប្រជាជនគន្លឹះឱ្យបានយ៉ាងឆាប់រហ័សនិងបានទូលំទូលាយ។

៥- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវណែនាំរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់លើកផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងប្រើប្រាស់ថវិកាតាមសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព។

៦- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PrEP) សេវាបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PEP) និងលើកទឹកចិត្តការប្រើប្រាស់ស្រោមអនាម័យឱ្យមានប្រសិទ្ធភាពជាប្រចាំដល់ក្រុមគោលដៅ ព្រមទាំងខិតខំទប់ស្កាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានប្រសិទ្ធភាពខ្ពស់។

៧- ក្រសួងសុខាភិបាលបន្តពង្រឹង ពង្រីកសេវាថែទាំព្យាបាល អ្នកផ្ទុកមេរោគអេដស៍ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

៨- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវផ្តល់របាយការណ៍នៃការអនុវត្តថវិកាឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់។

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥

**ប្រធានអង្គប្រជុំ**
**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**